**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សារលិខិតជូនពរ

**គោរពជូន**

**ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**ឯកឧត្តមរដ្ឋមន្ត្រី ជាទីគោរពរាប់អាន**!

ក្នុងឱកាសដ៏បវរសួស្តី សិរីមង្គលមហាប្រសើរ នៃពិធីចម្រើនជន្មាយុគម្រប់៧១ឆ្នាំ ឈានចូល៧២ឆ្នាំ របស់ **ឯកឧត្តមរដ្ឋមន្ត្រី** នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្តែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅ ជូនចំពោះ **ឯកឧត្តមរដ្ឋមន្ត្រី** សូមប្រកបដោយសុខភាពល្អបរិបូណ៌ មានកាយពលមាំមួន បញ្ញាញាណវាងវៃ និងជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏មហាប្រពៃនេះ យើងខ្ញុំសូមអនុញ្ញាតសម្តែងនូវការកោតសរសើរដោយស្មោះ ចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** នៅក្នុងបេសកកម្មដឹកនាំក្រសួងព័ត៌មាន សម្រេចបាននូវសមិទ្ធផលជាច្រើនជាប្រវត្តិសាស្ត្រដើម្បីបម្រើជាតិ និងប្រជាជន រួមចំណែកយ៉ាងសំខាន់ដល់ការរក្សាបាននូវ សុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ប្រោសប្រទានពរជ័យជូនចំពោះ **ឯកឧត្តម ខៀវ កាញារីទ្ធ និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** មានសុខភាពល្អបរិបូរណ៍ និងទទួលបានពុទ្ធពរដ៏មហាប្រសើរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ៕

ថ្ងៃ ចន្ទ ២ រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុន សុខា**